# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាអគ្គសញ្ញាតែងតាំងជាបូជាចារ្យរបស់បងប្រុស ប៉ូល និងបងប្រុស យ៉ូសែប
# ផ្សារតូច ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩
# បាទគឺខ្ញុំនេះហើយ

**អត្ថបទទី១៖ អេសាយ ៦,១-៨**

ខ្ញុំឮព្រះសូរសៀងរបស់ព្រះអម្ចាស់ដែលមានព្រះបន្ទូលថា៖ «តើយើងនឹងចាត់អ្នកណាឲ្យទៅ តើនរណានឹងនាំពាក្យរបស់យើង?»។ អស ៦,៨

**អត្ថបទទី២៖ កូរិនថូសទី១ ៩,១៣-១៩**

ខ្ញុំមិនត្រូវអួតថាការផ្សាយដំណឹងល្អជាកិត្តិយសរបស់ខ្ញុំនោះទេ ព្រោះជាភារកិច្ចមួយដែលខ្ញុំត្រូវតែធ្វើដោយខានមិនបាន។ ប្រសិនបើខ្ញុំមិនផ្សាយដំណឹងល្អទេ សូមឲ្យខ្ញុំវេទនាទៅចុះ!។ ១ករ ៩,១៦

**ដំណឹងល្អ៖ ម៉ាថាយ ២៨,១៦-២០**

ត្រូវបង្រៀនគេឲ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក។ មថ ២៨,២០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាអំណរសប្បាយសម្រាប់ព្រះសហគមន៍កម្ពុជាទាំងមូល បងប្រុសទាំងពីរនាក់ដែលនឹងទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យថ្ងៃនេះ មិនដូចយើងទាំងអស់គ្នាជាបូជាចារ្យជាសាសនទូតមកពីប្រទេសផ្សេងៗ។ ជាសាសនទូតដែលទទួលអគ្គសញ្ញាតែងតាំងនៅក្នុងភូមិភាគភ្នំពេញ លោកបូជាចារ្យទាំងអស់ដែលនៅទីនេះបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅតាមប្រទេសរៀងៗខ្លួន។ ទាំងពីរនាក់ តាមពីពេលនេះតទៅភូមិភាគកំណើតរបស់គេគឺភូមិភាគភ្នំពេញ ទៅជាបងប្អូនបង្កើតពិសេសជាមួយលោកបូជាចារ្យខ្មែរ ជាមួយលោកបូជាចារ្យទាំងអស់ដែលបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជា។

ថ្ងៃនេះ យើងបានស្ដាប់អត្ថបទបីដែលណែនាំឲ្យយើងភ្ញាក់ស្មារតី អត្ថបទទី១ "**តើយើងនឹងចាត់អ្នកណាឲ្យទៅ តើនរណានឹងនាំពាក្យរបស់យើង?**" អត្ថបទទី២ "**ប្រសិនបើខ្ញុំមិនផ្សាយដំណឹងល្អទេ សូមឲ្យខ្ញុំវេទនាទៅចុះ!**" គម្ពីរដំណឹងល្អ "**ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឲ្យធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកឲ្យគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ**"។ ខ្ញុំសូមអរគុណដល់ ប៉ូល និងយ៉ូសែប ដែលបានជ្រើសរើសអត្ថបទនេះធ្វើឲ្យយើងចូលនៅក្នុងអាទិភាពនៃជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដែលបានទទួលពិធីជ្រមុជទឹក។ ប្រកាសអំពីព្រះយេស៊ូគ្រីស្ត ព្រះយេស៊ូគ្រីស្តដែលសោយទិវង្គត ព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មគង់នៅថ្ងៃនេះៗ នេះមិនមែនអ្វីដែលយើងអាចជ្រើសរើសប្រកាសឬមិន

ប្រកាសតាមចិត្ត ប៉ុន្តែនេះជាលក្ខណៈនៃព្រះសហគមន៍របស់យើង គឺប្រកាសដំណឹងល្អដល់មនុស្សទាំងអស់នៅលើផែនដីនេះ។

នៅពេលយើងចាប់ផ្តើមពិធីខ្ញុំបានត្រាស់ហៅទាំងពីរនាក់ ហើយយើងបានស្តាប់ឮយ៉ាងច្បាស់ចម្លើយរបស់គេគឺ "**បាទ! គឺខ្ញុំនេះហើយ**"។ នេះជាបាទមួយយ៉ាងពិសេសនៅក្នុងជីវិត បាទធំបំផុតដែលបានប្រកាសនៅមុខយើងទាំងអស់គ្នា នៅមុខព្រះសហគមន៍ នៅមុខព្រះជាម្ចាស់ផ្ទាល់។ បាទ ដែលបានប្រកាសថ្ងៃនេះអាចប្រកាសបាន ដោយសារនៅក្នុងជីវិតពីដើមរៀងមកដែលធ្វើដំណើរជាមួយព្រះយេស៊ូ ដែលធ្វើដំណើរជាមួយព្រះសហគមន៍។ ចម្លើយ បាទ ថ្ងៃនេះជាចម្លើយសរុបគ្រប់បាទទាំងអស់ដើម្បីឯកភាព ពិតមែនខ្ញុំនេះហើយ សុខចិត្តបម្រើព្រះជាម្ចាស់និងព្រះសហគមន៍អស់មួយជីវិត។ បាទ ដែលយើងប្រកាសថ្ងៃនេះមិនមែនជាបាទចុងក្រោយទេ ដោយសារជារៀងរាល់ថ្ងៃនៅពេលយើងភ្ញាក់ពីដេក ជាឱកាសមួយដើម្បីយើងនិយាយទៅព្រះជាម្ចាស់ ទៅព្រះយេស៊ូ "**ឱព្រះយេស៊ូអើយ! បាទគឺខ្ញុំនេះហើយ**"។ សម្រាប់យើងដែលជាអភិបាល ជាបូជាចារ្យ ជាបុព្វជិតបុព្វជិតា ជាគ្រីស្តបរិស័ទ នៅពេលយើងបានស្តាប់ "**បាទគឺខ្ញុំនេះហើយ**" ណែនាំឲ្យយើងកក់ក្តៅនៅក្នុងខ្លួនរបស់យើង ដោយសារយើងនឹករលឹកដល់ថ្ងៃដែលយើងបាននិយាយបាទដែរ។ សម្រាប់ក្រុមគ្រួសារក៏ដូចគ្នាដែរ នៅពេលយើងសុខចិត្តយកគ្នាជាប្តីប្រពន្ធនៅមុខព្រះជាម្ចាស់យើងបាននិយាយដែរថា បាទអស់មួយជីវិតទោះបីជាក្នុងគ្រាលំបាក គ្រាអំណរ សុខចិត្តធ្វើដំណើរជាមួយគ្នា។ សម្រាប់យុវជន នៅពេលអនាគតយើងអាចនិយាយបាទអ្វីខ្លះដើម្បីរៀបចំផ្លូវនឹងឆ្លើយតបការត្រាស់ហៅរបស់ព្រះជាម្ចាស់។ សម្រាប់បងប្អូនដែលចាស់ហើយ យើងកំពុងត្រៀមបាទដែលយើងបាននិយាយយូរឆ្នាំហើយ ដើម្បីជួបជាមួយព្រះជាម្ចាស់នៅខាងមុខ។ ពិតមែន យើងទាំងអស់គ្នាធ្លាប់និយាយថា បាទគឺខ្ញុំនេះហើយ នៅពេលនេះនិងនៅថ្ងៃអនាគតទៀត។

**តើយើងនឹងចាត់អ្នកណាឲ្យទៅ តើនរណានឹងនាំពាក្យរបស់ខ្ញុំ?** ទូលបង្គំនៅទីនេះស្រាប់ហើយ សូមព្រះអង្គចាត់ទូលបង្គំចុះ នេះជាចម្លើយរបស់បងប្រុសទាំងពីរនាក់ថ្ងៃនេះ។ បាទរបស់យើងប្លែកដោយសារបន្តិចទៀតខ្ញុំទ្រាបដៃ ដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធទាំងពីរនាក់បានភ្ជាប់ក្នុងរបៀបពិសេសជាមួយព្រះយេស៊ូគ្រីស្តផ្ទាល់។ ការប្លែកគ្នានេះ ជាការប្លែកដែលយើងមើលមិនឃើញ ដោយសារយើងជាមនុស្សដូចគេឯង ប៉ុន្តែដោយការទ្រាបដៃ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធយើងទៅជាមនុស្សប្លែកដោយជាប់ជាមួយព្រះយេស៊ូ ដែលមានអំណាច ដែលមានឫទ្ធានុភាពដើម្បីប្រគល់ជីវិតរបស់ព្រះគ្រីស្ត តាមរយៈអគ្គសញ្ញាព្រះកាយព្រះគ្រីស្តពេលអភិបូជា និងមានឫទ្ធានុភាពដើម្បីលើកលែងទោសរំដោះបាប ដោយនាមព្រះជាម្ចាស់ផ្ទាល់។ ចាប់ពី

ពេលនេះតទៅ ពាក្យដែលចេញពីបបូរមាត់អាចប្រទានទាំងការលើកលែងទោស ទាំងជីវិតរបស់ព្រះគ្រីស្តតាមរយៈព្រះកាយនិងព្រះលោហិតរបស់ព្រះយេស៊ូ។ ហេតុនេះហើយ ចាប់ពីពេលនេះតទៅបងប្រុសទាំងពីរនាក់ទៅជាមនុស្សប្លែក ប្លែកពីយើងទាំងអស់តែចូលនៅក្នុងមហាគ្រួសារនៃបូជាចារ្យ។ សូមអរគុណដល់ក្រុមគ្រួសារទាំងពីរ សម្រាប់អំណោយដែលគ្រួសារជូនដល់ព្រះសហគមន៍នៅប្រទេសកម្ពុជា។

សូមបងប្អូនអធិដ្ឋាន ដើម្បីឲ្យយុវជនយុវនារីរបស់យើង អាចស្តាប់ឮសំណួរនេះ **តើយើងនឹងចាត់អ្នកណាឲ្យទៅ តើនរណានឹងនាំពាក្យរបស់ខ្ញុំ?** ឲ្យយើងឆ្លើយដើម្បីណែនាំឲ្យគេមានសេចក្តីសុខនៅក្នុងខ្លួន។ ដោយដឹងថា រហូតដែលគេមិនឆ្លើយតបទូលបង្គំនៅទីនេះស្រាប់ហើយ គេរកមិនឃើញសេចក្តីសុខនៅក្នុងដួងចិត្ត។ បេសកកម្មដែលយើងនឹងទទួលចាប់ពីពេលនេះតទៅ ពិតមែនធ្វើពិធីជ្រមុជទឹកទៅ ពិតមែនព្យាបាលអ្នកជំងឺទៅ ពិតមែនប្រកាសដំណឹងល្អដោយជីវិតផ្ទាល់ខ្លួនទៅ ដោយសារព្រះជាម្ចាស់បានត្រាស់ហៅបងប្រុសទាំងពីរនាក់ឲ្យបម្រើព្រះសហគមន៍និងប្រទេសកម្ពុជាទាំងមូល។ កុំឲ្យយើងចង្អៀត នៅប្រទេសកម្ពុជាយើងមានប្រជាជនជាង ១៥លាននាក់ តែគ្រីស្តបរិស័ទយើងមានតែជាង២ម៉ឺននាក់ គឺយើងត្រូវតែទទួល១៥លាននាក់នោះ។ ដូច្នេះប៉ូលដែលត្រូវតែប្រកាសដំណឹងល្អនៅកំពង់ចាម និងយ៉ូសែប ដែលនឹងប្រកាសដំណឹងល្អតាមរបៀបសន្តយ៉ូហានបូស្កូ សូមគិតពិចារណា។

ប្រទេសកម្ពុជាយើងមានព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ខុសប្លែកពីប្រទេសដទៃទៀត ប៉ុន្តែនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គេបានឯកភាពឲ្យប្រជាជនកម្ពុជាទាំងអស់មានសិទ្ធិជ្រើសរើសសាសនាដែលគេចង់ដើរតាម។ យើងអរគុណដល់រាជរដ្ឋាភិបាល ដែលបានឯកភាពឲ្យយើងមានសិទ្ធិសេរីភាពដើម្បីកាន់សាសនា ដែលខ្លួនគិតថាជាសាសនាដែលណែនាំឲ្យយើងរកឃើញសេចក្តីពិតនិងជីវិតដ៏បរិបូណ៌។ នៅក្នុងប្រទេសជាច្រើនក្នុងពិភពលោកគ្មានសិទ្ធិសេរីភាពដូចនេះទេ។ ប្រកាស ព្យាបាល ធ្វើពិធីជ្រមុជទឹក កុំខ្លាចអី សូមសម្លឹងមើលព្រះយេស៊ូដើម្បីមើលរបៀបព្រះអង្គ។ ថ្ងៃនេះខ្ញុំសូមជូនរបៀបព្រះយេស៊ូប្រាំចំណុចសំខាន់ៗ គឺៈ

ទីមួយ **ព្រះយេស៊ូចាប់កំណើតជាមនុស្ស** ពីបេថ្លេហិមដល់ណាសារ៉ែត៣០ឆ្នាំមុនចាប់ផ្តើមធ្វើការ មុនចាប់ផ្តើមប្រកាស ព្យាបាល ៣០ឆ្នាំដើម្បីចាប់កំណើតជាមនុស្ស។ ដូច្នេះ ទាំងពីរនាក់សូមចាប់កំណើតជាមនុស្សនៅលើទឹកដីកម្ពុជាពិតៗ សូមចូលនៅក្នុងជីវិតប្រជារាស្ត្រកម្ពុជា សូមចូលនៅក្នុងជីវិតរបស់ព្រះសហគមន៍នៅប្រទេសកម្ពុជា។ យើងត្រូវតែលះបង់ចោលរបៀបយើងដែលជាជនជាតិថៃ ជនជាតិវៀតណាម និងជនជាតិនានា ដើម្បីចូលនៅក្នុងវប្បធម៌ថ្មី នៅក្នុងជីវិតថ្មីនៅក្នុងភាសាថ្មី ចាប់កំណើតជាមនុស្សមានន័យថាយើងយល់ចិត្តគ្នា។

ទីពីរ **សូមមើលព្រះយេស៊ូ** ព្រះអង្គពូកែនៅក្នុងការសន្ទនា ព្រះយេស៊ូប្រកាសដំណឹងល្អនៅធម្មសាលា ព្រះយេស៊ូដើរជាមួយសាសន៍ដទៃ។ ហេតុនេះហើយ ខ្ញុំចង់ឃើញលោកប៉ូល និងលោកយ៉ូសែប ទៅបង្កើតទំនាក់ទំនងជាមួយសាសនាដទៃ និយាយជាមួយប្រជារាស្ត្រកម្ពុជាយ៉ាងច្បាស់លាស់ និយាយជាមួយអាជ្ញាធរដែនដី។ កុំឲ្យយើងចូលនៅក្នុងរបៀបបង្ខំឲ្យគេចូលដោយដឹងថាមានតែសក្ខីភាពរបស់យើង ដែលណែនាំឲ្យបងប្អូនឯទៀតៗអាចឆ្លងសេចក្ដីស្រឡាញ់ ឆ្លងជំនឿ ឆ្លងជីវិតដ៏វិសុទ្ធពីយើង។ ផ្ដល់សក្ខីភាព ដោយចូលនៅក្នុងការសន្ទនានៃជីវិតយ៉ាងពិតប្រាកដមែន។

ទីបី **សូមបើកចិត្តគំនិតទូលំទូលាយប្រកបដោយបរិយាបន** ណែនាំឲ្យទាំងជនពិការ ទាំងមិនពិការ ទាំងអ្នកមានជំងឺ ទាំងអ្នកគ្មានជំងឺ ទាំងមនុស្សធម្មតាឲ្យចូលគ្នាតែមួយធ្វើជាគ្រួសារតែមួយ។ សូមបើកចិត្តគំនិតទូលំទូលាយប្រកបដោយបរិយាបនដូចព្រះយេស៊ូ ព្រះអង្គនៅជាមួយអ្នកជំងឺ ព្រះអង្គនៅជាមួយអ្នកមានបាប ព្រះអង្គនៅជាមួយសាសន៍ដទៃ ដូច្នេះសូមបើកចិត្តគំនិតដើម្បីនៅជាមួយបងប្អូន។ កុំមើលងាយបងប្អូនឯទៀតៗ សូមមានពាក្យច្បាស់លាស់ដោយពោរពេញដោយការគោរពគ្នាទៅវិញទៅមក។ យើងត្រូវការមើលព្រះយេស៊ូ ដោយយកអ្នកក្រីក្រជាអាទិភាពជានិច្ច ជាពិសេសយកចិត្តទុកដាក់បង្កើតទីតាំង កន្លែង សកម្មភាពទូលំទូលាយនៅតាមព្រះសហគមន៍របស់យើង ដើម្បីទទួលស្វាគមន៍មនុស្សទាំងអស់នៅក្នុងបរិយាបន។

ទីបួន **សួរសុខទុក្ខ** យើងមិនតែទៅមើលគេយើងទៅសួរសុខរបស់គេ ទុក្ខរបស់គេ មានន័យថាយើងបានបង្កើតទំនាក់ទំនងជាមួយគេ។ ព្រះយេស៊ូអញ្ជើញខ្លួនឯងទៅផ្ទះលោកសាខេ ទៅផ្ទះលោកសាឡា ម៉ាថា និងម៉ារី ប៉ុន្មានដងប៉ុន្មានសារយើងឃើញព្រះយេស៊ូកំពុងហូបបាយដើម្បីយកពេលវេលាសួរសុខទុក្ខគេ។ ដូច្នេះ ប៉ូល និងយ៉ូសែប កុំបិទទ្វារនិងចូលនៅតែក្នុងការិយាល័យ សន្តយ៉ូហានបូស្កូបានលេងបាល់ជាមួយយុវជនដើម្បីភ្ជាប់ជាមួយគេ។ ឲ្យយើងដើរពីផ្ទះមួយទៅផ្ទះមួយ ដោយស្ដាប់សម្លេងបងប្អូន សួរសុខទុក្ខបងប្អូន នេះគឺព្រះជាម្ចាស់ដែលទៅសួរសុខទុក្ខបងប្អូន។ នៅសម័យលោកអាប្រាហាំ នៅពេលគាត់ទទួលភ្ញៀវបីនាក់គឺព្រះជាម្ចាស់ដែលបានស្វាគមន៍ផ្ទាល់ យើងជាភ្ញៀវហើយបងប្អូនដែលស្វាគមន៍យើងជាលោកអាប្រាហាំ មានន័យថាជាព្រះជាម្ចាស់តាមរយៈយើង។

ទីប្រាំ **សូមរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់** ព្រះយេស៊ូបានអធិដ្ឋាននៅលើភ្នំពីព្រឹក ព្រះយេស៊ូទូលអង្វរទៅព្រះបិតាគ្រប់ពេលវេលាមុនព្រះអង្គរៀបចំការអស្ចារ្យមួយ ព្រះយេស៊ូអរព្រះគុណព្រះបិតា។ សង្ឃឹម ប៉ូល និងយ៉ូសែប ភ្ញាក់ពីព្រលឹមដើម្បីអធិដ្ឋាន ចូលដេកយប់ជ្រៅដោយសារអធិដ្ឋាន។ បូជាចារ្យជាបុព្វជិត បូជាចារ្យជាសាសនទូតនៅក្នុងលោកិយប៉ុន្តែមិនមកពី

លោកិយ ការអធិដ្ឋានរបស់ព្រះយេស៊ូជាបូជាចារ្យ ជាមហាបូជាចារ្យដែលទូលអង្វរព្រះបិតាឲ្យយើងជាអង្គតែមួយ ដើម្បីឲ្យមនុស្សយើងទាំងអស់គ្នាទៅជាអង្គតែមួយដែរ។ អង្គតែមួយជាមួយបូជាចារ្យ អង្គតែមួយជាគ្រីស្តបរិស័ទ អង្គតែមួយជាមួយប្រជារាស្ត្រដែលស្វាគមន៍យើង ដើម្បីរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់។ ដូចព្រះនាងម៉ារី ដែលបានច្រៀងកោតសរសើរអស់ពីដួងចិត្ត ដោយសារព្រះនាងម៉ារីរស់នៅក្នុងដង្ហើមនិងបរិយាកាសរបស់ព្រះជាម្ចាស់គ្រប់ពេលវេលា។

លោកប៉ូល និងលោកយ៉ូសែប នៅពេលលោកអភិបាលនិងលោកបូជាចារ្យបានទ្រាបដៃនៅពេលយើងបានទូលអង្វរឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ខ្ញុំនឹងជូនចានព្រះកាយនិងពែងស្រា ដោយនិយាយថាចូរទទួលដង្វាយពីប្រជារាស្ត្រដ៏វិសុទ្ធ ដើម្បីយកទៅថ្វាយព្រះជាម្ចាស់។ ចូរចាប់អារម្មណ៍ពីអត្ថន័យនៃអភិបូជា ចូររស់នៅឲ្យបានស្របតាមសក្ការៈបូជាដែលប្អូននឹងថ្វាយ ចូរយកគម្រាប់តាមព្រះគ្រីស្តដែលបានបូជាព្រះជន្មនៅលើឈើឆ្កាង។ ប្រជារាស្ត្រដ៏វិសុទ្ធគឺបងប្អូនទាំងអស់ ប្រជារាស្ត្រដ៏វិសុទ្ធដែលបូជាចារ្យបម្រើគឺបងប្អូនទាំងអស់ ប្រជារាស្ត្រដ៏វិសុទ្ធដែលបូជាចារ្យសុខចិត្តលះបង់ចោលដើម្បីជូន ថ្វាយ ស្រឡាញ់គឺបងប្អូនទាំងអស់។ ថ្ងៃនេះបងប្អូនដែលជាព្រះសហគមន៍កាតូលិកទូទាំងប្រទេសកម្ពុជា សូមអធិដ្ឋានដោយទូលអង្វរសម្រាប់បូជាចារ្យថ្មីទាំងពីរនាក់ប៉ូលនិងយ៉ូសែប និងសម្រាប់បូជាចារ្យទាំងអស់ដែរ ដើម្បីឲ្យយើងជាអ្នកបម្រើរបស់ព្រះយេស៊ូគ្រីស្ត ដែលជាមហាបូជាចារ្យតែមួយគត់ដើម្បីឲ្យយើងរៀបចំបេះដូងរបស់យើង សេចក្តីស្រឡាញ់របស់យើងតាមព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ អាម៉ែន៕